

ដោយអែលឌើរ ក្លាក ជី ហ្គីលបឺត
នៃពួកចិតសិបនាក់

# អំណាចនៃ ការរៀនសូត្រ

ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនមែនជាមនុស្សរៀនពូកែទេ ពេលខ្ញុំធំឡើង ។ បងប្អូនបង្កើតទាំងអស់របស់ខ្ញុំពិតជាឆ្លាត។ណាស់ ។ ពួកគេទទួលបានពិន្ទុល្អ ។ ពួកគេបានរៀនថ្នាក់ពិបាកបំផុត ។ ខ្ញុំបានបន្តព្យាយាមចុះឈ្មោះរៀនថ្នាក់ពិលំបាកបំផុត ប៉ុន្តែខ្ញុំមិនដែលទទួលបានការអនុញ្ញាតឲ្យចូលរៀនឡើយ ។ ថ្នាក់គណិតវិទ្យាគឺពិតជាពិបាកណាស់ ។ ដូច្នេះខ្ញុំបានគិតថា « ប្រហែលខ្ញុំមិនឆ្លាតទេ » ។ ខ្ញុំគិតថារឿងនោះមិនអាចផ្លាស់ប្ដូរបានទេ ។

ក្រោយមកក្នុងរយៈពេលមួយឆ្នាំ ខ្ញុំមានអ្នកគ្រូម្នាក់ដែលបានផ្ដល់ទំនុកចិត្តដែលខ្ញុំត្រូវការ ។ អ្នកគ្រូរបស់ខ្ញុំបានមើលឃើញទេពកោសល្យជាច្រើនរបស់ខ្ញុំ ច្រើនជាងខ្ញុំ ។ គាត់បាននិយាយថា « ក្លាក ឯងអាចក្លាយជាសិស្សពូកែម្នាក់ ។ ឯងគ្រាន់តែត្រូវជឿលើខ្លួនឯងប៉ុណ្ណោះ » ។

ដូច្នេះ ខ្ញុំបានបន្តព្យាយាម ។ ខ្ញុំខំសិក្សាកាន់តែខ្លាំង ។ ខ្ញុំក៏បានខំធ្វើការដើម្បីឲ្យកាន់តែមានរបៀបរៀបរយកាន់តែច្រើន ។ ខ្ញុំបានរៀនអំពីរបៀបតាមដានកិច្ចការផ្ទះរបស់ខ្ញុំ ។ ការបិទទូរទស្សន៍បានជួយខ្ញុំឲ្យផ្ដោតអារម្មណ៍ទៅលើកិច្ចការសាលារបស់ខ្ញុំ ។ មិនយូរប៉ុន្មានខ្ញុំបានក្លាយជាសិស្សដ៏ល្អប្រសើរម្នាក់ ។ ហើយទំនុកចិត្តរបស់ខ្ញុំបានកើនឡើង ។

ពេលខ្ញុំទៅបេសកកម្ម ខ្ញុំបានឃើញថាខ្ញុំមិនចាំបាច់រៀនដោយខ្លួនឯងទេ ។ ខ្ញុំបានទូលសុំជំនួយពីព្រះវរបិតាសួគ៌។ ហើយខ្ញុំបានស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធ ។ កាលខ្ញុំខិតខំធ្វើការ ខ្ញុំអាចបង្រៀន និងជួយមនុស្សបាន ។ នៅពេលខ្ញុំត្រឡប់មកពីបេសកកម្មវិញ ខ្ញុំបានចូលរៀនមហាវិទ្យាល័យ ។ ខ្ញុំបានអធិស្ឋានទូលសុំជំនួយពីព្រះគ្រប់ថ្នាក់ទាំងអស់ ។ ខ្ញុំបានក្លាយជាសិស្សល្អជាងមុន ហើយថែមទាំងចាប់ផ្ដើមស្រលាញ់មុខវិជ្ជាគណិតវិទ្យាផងដែរ !

ខ្ញុំបានគិតថាភាពឆ្លាតវៃមានន័យថាយើងចេះច្រើន ហើយការរៀននៅសាលាគឺងាយស្រួល ។ នោះមិនពិតទេ ។ ប្រសិនបើក្មួយមានឆន្ទៈឲ្យព្រះអម្ចាស់ចូលរួមជាមួយនៅក្នុងការរៀនសូត្ររបស់ក្មួយ ហើយខិតខំរៀនសូត្រ នោះក្មួយនឹងឆ្លាតវៃ !

ប្រសិនបើអ្វី។ពិបាកឥឡូវនេះ សូមចាំថាក្មួយគឺជាកូនរបស់ព្រះ ។ ក្មួយមានសក្ដានុពលដ៏អស្ចារ្យ ។ ក្មួយអាចធ្វើកិច្ចការពិបាក។បាន ។ គ្រាន់តែបន្តអនុវត្ត ។ អធិស្ឋានទូលសុំជំនួយពីព្រះវរបិតាសួគ៌ ។ ទ្រង់ចង់ឲ្យក្មួយជោគជ័យ ។ ក្មួយអាចធ្វើវាបាន ! ●

*ដកស្រង់មកពីការសម្ភាសមួយជាមួយ អូលីវ៉ា ឃីធីមែន និងណូអែល ឡាមបឺត បារ៉ុស ។*





## ការរៀនសូត្រសប្បាយណាស់

ស្វែងរកគំរូនីមួយ។នៃសម្ភារសិក្សានៅក្នុងក្រឡាចត្រង្គខាងក្រោម ។ តើប្អូនចូលចិត្តរៀនអ្វីនៅសាលា ?





« ស្វែងរកពាក្យសម្ដីនៃប្រាជ្ញារាងវ៉ចេញពីសៀវភៅដ៏ល្អ។បំផុត ចូរស្វែងរកការរៀនសូត្រ គឺដោយសារការសិក្សា និងដោយសារសេចក្ដីជំនឿផង » ។
( គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៩:៧ ) ។